ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១០៣៧៩ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ២០១៧

**ជម្រាបជូន**

**ឯកឧត្តមសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល**

**កម្មវត្ថុ**: ករណីសំណើសុំការអនុញ្ញាតសម្រេចជ្រើសរើសនិងប្រគល់កិច្ចសន្យា ស្តីពីការងាររៀបចំសាលប្រជុំ និងបញ្ចារបង់ប្រាក់នៅជាន់ផ្ទាល់ដីអគារ M, រៀបចំបណ្ណាល័យជាន់ទី១និងជាន់ទី២ អគារសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន (អគារទី៣), រៀបចំផ្លូវដើរក្នុងបរិវេណ IMK នៅទីតាំងទី១ និងរៀបចំក្លោងទ្វារតូបយាមនិងផ្លូវចូលនៅទីតាំងទី២ ។

**យោង** :
- លិខិតលេខ១៤៨៤ ស.វ.ស ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧ របស់សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល
- លិខិតលេខ៦០៩ សនថហ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧ របស់ក្រសួងសុខាភិបាល
- កំណត់ហេតុបើកឯកសារដេញថ្លៃចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៧ របស់គណៈកម្មាធិការលទ្ធកម្មសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល
- កំណត់ហេតុវាយតម្លៃប្រគល់កិច្ចសន្យាចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៧ របស់គណៈកម្មាធិការលទ្ធកម្មសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល
- លិខិតលេខ១៥០ អល/ស.វ.ស ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ របស់សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមសាកលវិទ្យាធិការមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុយល់ព្រមតាមសំណើរបស់សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ក្នុងការប្រគល់កិច្ចសន្យាជូនក្រុមហ៊ុន គីម ហួយ អ៊ាង អ៊ីមផត អិចផត អេន ខនស្ត្រាក់សិន ដើម្បីរៀបចំសាលប្រជុំ និងបញ្ចារបង់ប្រាក់នៅជាន់ផ្ទាល់ដីអគារ M, រៀបចំបណ្ណាល័យជាន់ទី១និងជាន់ទី២ អគារសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន (អគារទី៣), រៀបចំផ្លូវដើរក្នុងបរិវេណ IMK នៅទីតាំងទី១ និងរៀបចំក្លោងទ្វារតូបយាមនិងផ្លូវចូលនៅទីតាំងទី២ ក្នុងតម្លៃសរុបចំនួន ១ ១៥០ ៦៧៧ ៣០០ រៀល (មួយពាន់លាន មួយរយហាសិបលាន ប្រាំមួយរយចិតសិបប្រាំពីរពាន់ បីរយរៀលគត់) ជាតម្លៃកិច្ចសន្យា ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមសាកលវិទ្យាធិការមេត្តាជ្រាបនិងមានវិធានការអនុវត្តបន្តឱ្យសមស្របតាមនីតិវិធីលទ្ធកម្មសាធារណៈតាមការគួរ ។

សូមឯកឧត្តមសាកលវិទ្យាធិការទទួលនូវការគោរពរាប់អានពីខ្ញុំ ។

ឋ. ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
អនុរដ្ឋលេខាធិការ

ហ៊ីង សុវណ្ណ

**ចម្លងជូន** :
- អគ្គនាយកដ្ឋានពន្ធដារ
- ក្រុមហ៊ុន គីមហួយ អ៊ាង អ៊ីមផត អិចផត អេន ខនស្ត្រាក់សិន
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798